ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# បរិស្ថាននិងសុខភាព



បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២

គាំទ្រដោយ : **អង្គការសុខភាពពិភពលោក**

# មាតិកា


១- សេចក្តីផ្តើម ........ ២

២- ចក្ខុវិស័យ ........ ៣

៣- គោលបំណងនិងគោលដៅ ........ ៣

  ៣.១- គោលបំណង ........ ៣

  ៣.២- គោលដៅ ........ ៣

៤- យុទ្ធសាស្ត្រ ........ ៤

  ៤.១- ការសម្របសម្រួលអន្តរស្ថាប័ន ........ ៤

  ៤.២- ការគ្រប់គ្រងប្រព័ន្ធព័ត៌មានបរិស្ថាននិងសុខភាព ........ ៤

  ៤.៣- ការកំណត់និងការវាយតម្លៃមុខសញ្ញាគ្រោះថ្នាក់បរិស្ថានដែលទាក់ទងនឹងសុខភាព ........ ៥

  ៤.៤ - ការគ្រប់គ្រងហានិភ័យ ........ ៥

  ៤.៥- ការគាំទ្រចាំបាច់សម្រាប់សេវាបរិស្ថាននិងសុខភាព ........ ៥

  ៤.៦- ការបណ្តុះបណ្តាលនិងការអប់រំវិជ្ជាជីវៈ ........ ៦

  ៤.៧- ការអប់រំនិងការផ្សព្វផ្សាយសាធារណៈ ........ ៦

  ៤.៨- ការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យា ........ ៦

  ៤.៩- កិច្ចសហការអន្តរជាតិ ........ ៧

  ៤.១០- សុខដុមនីយកម្មវិស័យនានា ........ ៧

៥- ផែនការសកម្មភាព ........ ៧

  ៥.១- ការបង្កើតយន្តការ ........ ៧

  ៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត ........ ៨

  ៥.៣- ការគាំទ្រហិរញ្ញវត្ថុ ........ ៨

  ៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស ........ ៩

  ៥.៥- ដំណើរការអនុវត្តគម្រោង ........ ៩

៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ........ ៩

៧- សេចក្តីសន្និដ្ឋាន ........ ៩

៨- សទ្ទានុក្រម ........ ១១

## ១- សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាបានចូលរួមក្នុងការផ្តួចផ្តើមថ្នាក់តំបន់របស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)និងអង្គការសុខភាពពិភពលោក(WHO)លើបញ្ហាសុខភាព ជាមួយប្រទេសអាស៊ីអាគ្នេយ៍និងប្រទេសអាស៊ីប៉ាស៊ីហ្វិកខាងលិច នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ឆ្នាំ២០០៤ នៅទីក្រុងបាងកក ប្រទេសថៃ ឆ្នាំ ២០០៧ និងនៅកោះជេជូ ប្រទេសកូរ៉េខាងត្បូង ឆ្នាំ២០១០ ក្នុងគោលបំណងចូលរួមទប់ស្កាត់ហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់សុខភាព ដែលបង្កដោយមនុស្សនិងបាតុភូតធម្មជាតិ។

ទន្ទឹមនឹងការអភិវឌ្ឍលើគ្រប់វិស័យ ព្រះរាជាណាចក្រកម្ពុជាកំពុងធ្វើសមាហរណកម្មចូលក្នុងតំបន់និងអន្តរជាតិក្នុងស្ថានភាពដ៏ប្រសើរ។ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈយ៉ាងមុតស្រួចក្នុងការធ្វើឱ្យគុណភាពជីវិតកាន់តែប្រសើរឡើង។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គឺជំរុញនូវការអភិវឌ្ឍកិច្ចការពារបរិស្ថាននិងលើកកម្ពស់សុខភាពសាធារណៈ។

នៅក្នុងទសវត្សរ៍ថ្មីៗនេះ មានបញ្ហាបរិស្ថាននិងសុខភាពដែលប្រទេសកម្ពុជាជួបប្រទះនិងកំពុងទាមទារឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រនិងមានវិធានការការពារនូវរាល់បញ្ហាទាក់ទងនឹងសារធាតុគីមី វិទ្យុសកម្ម មេរោគ ដែលបំពុលទឹក ដី ខ្យល់ ចំណីអាហារ និងកង្វះការគ្រប់គ្រងសំណល់គ្រប់ប្រភេទរួមទាំងសរីរៈផ្សេងៗ ដែលបង្កគ្រោះថ្នាក់ឱ្យមានជំងឺ របួស ពិការភាព និងមរណភាពខ្ពស់ក្នុងចំណោមប្រជាជនកម្ពុជា។ ដូច្នេះ បញ្ហាបរិស្ថាននិងសុខភាពមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយប្រសិនបើបរិស្ថានត្រូវបានបំពុលនិងធ្វើឱ្យចុះអន់ថយនោះ គេមិនអាចរំពឹងថាមនុស្ស សត្វនឹងទទួលបាននូវសុខភាពល្អនិងរស់នៅប្រកបដោយសុខដុមរមនាឡើយ។

លក្ខខណ្ឌបរិស្ថាននិងសុខភាពនៅក្នុងប្រទេសកម្ពុជាតម្រូវឱ្យមានការកែលម្អគុណភាព ព្រោះមានបញ្ហាប្រឈមសំខាន់ៗ ដូចជាកង្វះខាតលទ្ធភាពទទួលបានបង្គន់អនាម័យគ្រប់គ្រាន់ លទ្ធភាពទទួលបានទឹកស្អាតប្រើ ការបំពុលខ្យល់អាកាសនៅក្នុងផ្ទះនិងក្រៅផ្ទះ ដោយសារផ្សែងបារី ឧស ឧស្ម័ន គ្រឿងចក្ររោងចក្រ និងយានយន្ត។ល។ សំណល់ពុលនិងប្រកបដោយគ្រោះថ្នាក់ គឺជាកង្វល់ដែលកំពុងលេចឡើងសំណល់រាវមួយចំនួនបានបញ្ចេញចោលទៅក្នុងបរិស្ថានដោយមិនបានធ្វើការសម្អាតត្រឹមត្រូវតាមគោលការណ៍បច្ចេកទេសហើយបានបង្ហូរចូលទន្លេ(រួមទាំងទន្លេមេគង្គផង) ស្ទឹង អូរ និងបឹងបួ។ រោងចក្រ សហគ្រាសជាទូទៅមិនទាន់មានបទដ្ឋានសមស្របនៅឡើយ កម្មករប្រឈមនឹងកម្តៅ ធូលី ខ្យល់កខ្វក់ ផ្សែង សំឡេងថ្លង់ និងរំញ័រ នៅក្នុងផលិតកម្មនិងអាជីវកម្ម។ គម្រោងអភិវឌ្ឍន៍មួយចំនួននាំឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើននៅក្នុងផ្នែកបរិស្ថាននិងសង្គម ដែលទាក់ទងនឹងសុខភាព ហើយហានិភ័យដែលពាក់ព័ន្ធមានឥទ្ធិពលយ៉ាងធំធេងទៅលើសុខភាពរបស់សហគមន៍។ បន្លែ ផ្លែឈើ ចំណីអាហារមានផ្ទុកដោយសារធាតុគីមី កង្វះអនាម័យ និងហួសកាលកំណត់ បានបង្កឱ្យមានជំងឺឆ្លងស្រួចស្រាល់និងជំងឺមិនឆ្លងរ៉ាំរ៉ៃ។

ក្រសួងសុខាភិបាលនិងក្រសួងបរិស្ថានបានឯកភាពធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហាបរិស្ថាននិងសុខភាព ដោយសារបញ្ហាបរិស្ថាននិងសុខភាពមួយចំនួនមានលក្ខណៈប្រទាក់ក្រឡាគ្នា។ គ្រប់ការអភិវឌ្ឍតែងតែធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ដូច្នេះស្ថាប័នដែលទទួលខុសត្រូវចំពោះបរិស្ថាននិងសុខភាពចាំបាច់ត្រូវធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ។ ការងារទាំងនេះអាចសម្រេចបានតាមរយៈការអភិវឌ្ឍសមត្ថភាពនៅថ្នាក់មូលដ្ឋាន ដើម្បីកំណត់អាទិភាពនៃបញ្ហាបរិស្ថាននិងសុខភាព ដោយធ្វើផែនការតាមដានត្រួតពិនិត្យ វាយតម្លៃ និងអនុវត្តវិធានការទប់ស្កាត់ ដើម្បីបង្កើតឬកែលម្អមធ្យោបាយចម្បងៗដែលមានស្រាប់ ក្នុងការគ្រប់គ្រងបរិស្ថាននិងសុខភាពប្រកបដោយប្រសិទ្ធភាពខ្ពស់។ មធ្យោបាយទាំងនេះ តម្រូវឱ្យមានក្របខ័ណ្ឌរដ្ឋបាលដែលឆ្លុះបញ្ចាំងពីភាពជាដៃគូរវាងគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ព្រមទាំងភាគីពាក់ព័ន្ធសាធារណៈ និងឯកជនដទៃទៀតនៅគ្រប់លំដាប់ថ្នាក់។

ការធ្វើឱ្យប្រសើរឡើងចំពោះការត្រួតពិនិត្យកត្តាបរិស្ថាននានា ដែលមានទំនាក់ទំនងទៅនឹងផលប៉ះពាល់អវិជ្ជមានទៅលើសុខភាពមនុស្ស គឺជាសមាសធាតុដ៏សំខាន់មួយនៃកិច្ចខិតខំប្រឹងប្រែងនានា ដូចជាការសិក្សាវាយតម្លៃពីបញ្ហាបរិស្ថាន ដោយកំណត់បង្ហាញអំពីសុខភាព នឹងទទួលបានការគាំទ្រយ៉ាងខ្លាំងក្នុងការលើកស្ទួយសុខភាព សុខុមាលភាព និងគុណភាពជីវិត។

## ២- ចក្ខុវិស័យ

គោលនយោបាយនេះ មានចក្ខុវិស័យផ្តោតលើការលើកកម្ពស់សុខភាពនិងគុណភាពជីវិតមនុស្សសត្វ រុក្ខជាតិ តាមរយៈការគ្រប់គ្រងគុណភាពបរិស្ថានឱ្យបានប្រសើរឡើង។

## ៣- គោលបំណងនិងគោលដៅ

### ៣.១- គោលបំណង

គោលនយោបាយនេះមានគោលបំណងធានាឱ្យប្រជាជនកម្ពុជាទាំងអស់ មានសុខភាពល្អនិងមានសុខុមាលភាពកាន់តែប្រសើរ តាមរយៈការកាត់បន្ថយជំងឺដែលលេចឡើងថ្មីៗ ដោយសារកត្តាហានិភ័យនៃការបំពុលបរិស្ថាននិងការប្រើប្រាស់សារធាតុគីមី។

### ៣.២- គោលដៅ

៣.២.១- បង្កើតរចនាសម្ព័ន្ធនិងថៃរក្សាយន្តការរបស់រាជរដ្ឋាភិបាលក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចជាតិ គឺត្រូវធ្វើការពិចារណាអំពីផលប៉ះពាល់ចំពោះសុខភាព និងត្រូវធានាការអនុវត្តឲ្យបានប្រសើរបំផុតចំពោះការការពារគុណភាពបរិស្ថាននិងសុខភាព ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់ និងការលើកស្ទួយសុខភាពនៅក្នុងបរិបទរបស់ខ្លួន។

៣.២.២- កែលម្អនូវអ្វីដែលពាក់ព័ន្ធដល់គុណភាពនិងទិន្នន័យអំពីកត្តាបរិស្ថាន ទៅលើសុខភាពដែលអាចកំណត់បាន(ពោលគឺកត្តាផ្នែករូបសាស្ត្រ គីមី និងជីវសាស្ត្រនៅក្នុងខ្យល់ ទឹក ដី អាហារ និងអេកូឡូស៊ីមនុស្សជាទូទៅ) ក្នុងគោលបំណងវិភាគស្ថានភាព និន្នាការ និងផលប៉ះពាល់។

៣.២.៣- ចាត់វិធានការគ្រប់គ្រងហានិភ័យ រួមទាំងនីតិកម្មទៅលើសកម្មភាពរបស់បុគ្គលនីមួយៗ ទាំងនៅក្នុងវិស័យឯកជន ទាំងនៅក្នុងវិស័យសាធារណៈ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃដោយឥតលម្អៀងលើមុខសញ្ញាគ្រោះថ្នាក់ និងដើម្បីពង្រឹងយន្តការនិយតកម្មដែលធានាថា វិធានការគ្រប់គ្រងទាំងនេះត្រូវបានអនុវត្តប្រកបដោយភាពម៉ឺងម៉ាត់និងសមធម៌។

៣.២.៤- អភិវឌ្ឍសមត្ថភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធ(រួមទាំងមន្ទីរពិសោធន៍និងសេវាគាំទ្រដទៃទៀត) នៅគ្រប់លំដាប់ថ្នាក់។ រាជរដ្ឋាភិបាលត្រូវផ្គត់ផ្គង់នូវសេវាសមស្រប និងគាំទ្រយន្តការគ្រប់គ្រង តាមដាន និងវាយតម្លៃ ប្រកបដោយប្រសិទ្ធភាពទៅលើកត្តាហានិភ័យផ្នែកបរិស្ថានដែលប៉ះពាល់សុខភាព។

៣.២.៥- លើកកម្ពស់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសសម្រាប់មន្ត្រីរដ្ឋបាលសាធារណៈ ដើម្បីមានមូលដ្ឋានក្នុងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពអំពីការគ្រប់គ្រងហានិភ័យចំពោះសុខភាពជាមួយវិស័យផ្សេងៗទៀត និងដើម្បីអនុវត្តគោលនយោបាយជាតិបរិស្ថាននិងសុខភាព។

៣.២.៦- លើកទឹកចិត្តនិងជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់សាធារណជនទូទៅ តាមរយៈការផ្តល់កម្មវិធីអប់រំនិងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបញ្ហាបរិស្ថាននិងសុខភាព។

៣.២.៧- លើកកម្ពស់សមត្ថភាពនៃការស្រាវជ្រាវនិងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍបច្ចេកទេសនៅក្នុងវិធីសាស្ត្រគ្រប់គ្រង តាមដាន និងវាយតម្លៃដែលទាក់ទងទៅនឹងបរិស្ថាននិងសុខភាព។

៣.២.៨- ជំរុញកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងពិភពលោក លើបញ្ហាបរិស្ថាននិងសុខភាព។

## ៤- យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណងនិងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖

### ៤.១- ការសម្របសម្រួលអន្តរស្ថាប័ន

ជាការចាំបាច់ត្រូវមានយន្តការសមស្របនៅថ្នាក់ជាតិមួយ សម្រាប់ការពិគ្រោះយោបល់និងការផ្លាស់ប្តូរព័ត៌មានជាទៀងទាត់អំពីការធ្វើផែនការនិងការធ្វើសេចក្តីសម្រេចចិត្ត ដែលមានសក្តានុពលនិងមានឥទ្ធិពលទៅលើសុខភាពមនុស្ស សត្វ និងរុក្ខជាតិ ដោយមានការចូលរួមពីសំណាក់តំណាងនានាមកពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងទីភ្នាក់ងារផ្សេងៗ។ ដើម្បីកំណត់មុខសញ្ញាគ្រោះថ្នាក់ ការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ ត្រូវ៖

- អនុវត្តនិងពិនិត្យមើលឡើងវិញជាប្រចាំ ទៅលើគោលនយោបាយជាតិស្តីពីបរិស្ថាននិងសុខភាព ដោយសហការជាមួយស្ថាប័នឬផ្នែកផ្សេងៗទៀត ដើម្បីអាចធ្វើសេចក្តីសម្រេចចិត្តសមស្រប ដែលមានអត្ថប្រយោជន៍សម្រាប់សុខភាពមនុស្ស សុខុមាលភាពបរិស្ថាន និងសេដ្ឋកិច្ចរបស់ប្រទេស
- បង្កើតយន្តការនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ឱ្យមានសមត្ថភាពក្នុងការកំណត់និងវាយតម្លៃបញ្ហាថ្នាក់មូលដ្ឋាន និងរៀបចំដំណោះស្រាយដោយមានការចូលរួមពីសាធារណជន
- រៀបចំប្រតិភូកម្មទំនួលខុសត្រូវប្រកបដោយប្រសិទ្ធភាពពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ។

### ៤.២- ការគ្រប់គ្រងប្រព័ន្ធព័ត៌មានបរិស្ថាននិងសុខភាព

- អភិវឌ្ឍសមត្ថភាពនៅថ្នាក់សមស្របដើម្បីតាមដានហេតុប៉ះពាល់បរិស្ថាននិងប្រមូលការវិភាគ ការបកស្រាយទិន្នន័យ ចាំបាច់ត្រូវផ្តោតទៅលើការពាក់ព័ន្ធនិងគុណភាពនៃទិន្នន័យ ដោយប្រើបច្ចេកទេសត្រួតពិនិត្យគុណភាពដែលមានការទទួលស្គាល់
- ប្រើទិន្នន័យនិងព័ត៌មានដែលរកឬទទួលបានពីប្រភពផ្សេងៗ ដើម្បីចៀសវាងភាពខ្វះខាតនិងជាន់គ្នាដោយផ្តោតទៅលើបញ្ហាដែលមានលក្ខណៈជាក់លាក់ចំពោះប្រទេសកម្ពុជា
- នៅថ្នាក់ជាតិនិងថ្នាក់ផ្សេងៗទៀត ត្រូវបង្កើតបណ្តាញមូលដ្ឋានទិន្នន័យស្ថិតិសុខភាពមួយ និងសមត្ថភាពក្នុងការភ្ជាប់ទិន្នន័យទៅនឹងព័ត៌មាននៅថ្នាក់មូលដ្ឋានអំពីផលប៉ះពាល់ ផលវិបាកនៃផលប៉ះពាល់ និងជំងឺដែលបណ្តាលមកពីកត្តាបរិស្ថាន។ ក្នុងការប្រើប្រាស់ទិន្នន័យនិងព័ត៌មាន ត្រូវពិចារណាអំពីក្រមសីលធម៌សមស្របចាំបាច់របស់ប្រភពព័ត៌មាននិងទិន្នន័យនីមួយៗ
- កែលម្អលទ្ធភាពទទួលបានឬចែកចាយប្រព័ន្ធព័ត៌មានបច្ចុប្បន្ន ដើម្បីឱ្យអ្នកប្រើប្រាស់អាចរកបានមូលដ្ឋានទិន្នន័យតាមអ៊ិនធឺណិត
- បង្កើតនិងកែលម្អឯកសារនៅក្នុងបណ្ណាល័យ ដោយទទួលស្គាល់បច្ចេកវិទ្យាបច្ចុប្បន្ននៅក្នុងការផ្តល់សេវាបណ្ណាល័យនិងព័ត៌មាន។

### ៤.៣- ការកំណត់និងការវាយតម្លៃមុខសញ្ញាគ្រោះថ្នាក់បរិស្ថានដែលទាក់ទងនឹងសុខភាព

- ផ្តល់នូវបញ្ជីផ្ទៀងផ្ទាត់ពេញលេញនិងនីតិវិធីសវនកម្មដែលអាចប្រើប្រាស់នៅថ្នាក់ជាតិដើម្បីកំណត់កត្តាបរិស្ថានដែលអាចមានផលប៉ះពាល់អវិជ្ជមានទៅលើសុខភាពមនុស្ស សត្វ និងរុក្ខជាតិ
- បង្កើតនីតិវិធីដើម្បីកែលម្អនិងធ្វើសុខដុមនីយកម្មដំណើរការវាយតម្លៃហានិភ័យផ្នែកបរិស្ថាននិងសុខភាពសម្រាប់រាជរដ្ឋាភិបាល និយោជក និងទីភ្នាក់ងារផ្សេងៗទៀតឱ្យធ្វើការពិចារណាទៅលើផលប៉ះពាល់
- កម្មវិធីនានាគួរផ្តោតទៅលើនីតិវិធីវាយតម្លៃហានិភ័យតាមបែបបរិមាណនិងគុណភាពដែលអនុញ្ញាតឱ្យមានការវាយតម្លៃផលប៉ះពាល់ជាសក្តានុពលទាក់ទងទៅនឹងហានិភ័យចំពោះសុខភាពមនុស្ស
- ការវាយតម្លៃហានិភ័យគួរធ្វើឡើងនៅទីតាំងជាក់លាក់ ដែលបច្ចុប្បន្នត្រូវបានចាត់ទុកថាជាអាទិភាពសម្រាប់ផលប៉ះពាល់អវិជ្ជមាន និងអាចកើតមានចំពោះសុខភាពមនុស្សឬបរិស្ថាន
- ការវាយតម្លៃហានិភ័យផ្នែកបរិស្ថាននិងសុខភាព(បែបគុណភាពឬបរិមាណ) ធ្វើឡើងទៅលើគោលនយោបាយ គម្រោង និងកម្មវិធីថ្មីៗ។ នេះគឺជាផ្នែកមួយនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងការវាយតម្លៃផលប៉ះពាល់សុខភាព។

### ៤.៤- ការគ្រប់គ្រងហានិភ័យ

- រៀបចំផែនការប្រតិបត្តិការមួយដើម្បីធានាថាអន្តរាគមន៍ផ្នែកបរិស្ថាននិងសុខភាព ដែលអនុវត្តនៅក្នុងផែនការជាតិស្តីពីបរិស្ថាននិងសុខភាពត្រូវបានអនុវត្ត និងមានវិធានការបន្ថែមជាច្រើនទៀតត្រូវបានកំណត់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន
- តាមដាននិងពិនិត្យមើលឡើងវិញជាទៀងទាត់ទៅលើយន្តការដែលមានស្រាប់និងថ្មីៗ សម្រាប់ការវាយតម្លៃនិងការគ្រប់គ្រងផលប៉ះពាល់ផ្នែកសុខភាព ដែលបណ្តាលមកពីបម្រែបម្រួលបង្កឡើងដោយការអភិវឌ្ឍចំពោះកត្តាកំណត់ផ្នែកបរិស្ថាននិងសុខភាព និងគប្បីផ្តោតលើការបង្កើនប្រសិទ្ធភាពចំណាយលើអន្តរាគមន៍
- ពិនិត្យមើលឡើងវិញទៅលើប្រសិទ្ធភាពនិងនិរន្តរភាពនៃអន្តរាគមន៍ដែលប្រើប្រាស់នៅក្នុងប្រទេសមួយចំនួន និងត្រូវជ្រើសរើសចំពោះភាពដែលអាចយកមកប្រៀបធៀបបានរបស់ប្រទេសទាំងនោះជាមួយប្រទេសកម្ពុជា ទាក់ទងទៅនឹងដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងគោលដៅរបស់ខ្លួនសម្រាប់រយៈពេលបីឆ្នាំ ប្រាំឆ្នាំ និងដប់ឆ្នាំ
- ណែនាំអំពីវិធានការវាយតម្លៃនិងគ្រប់គ្រងហានិភ័យថ្មីៗ ដូចជាការកំណត់វិធានការផ្អែកលើបរិបទសុខភាពនូវការវាយតម្លៃហានិភ័យបែបបរិមាណឬគុណភាពអំពីអតិសុខុមប្រាណ។ ការរៀបចំវិធីសាស្ត្រគ្រប់គ្រងហានិភ័យ ដោយការធ្វើឱ្យកាន់តែទំនើបនូវបច្ចេកវិទ្យាក្នុងការពិនិត្យតាមដាន។

### ៤.៥- ការគាំទ្រចាំបាច់សម្រាប់សេវាបរិស្ថាននិងសុខភាព

- យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពធនធានមនុស្សសមស្រប ដើម្បីផ្តល់នូវការគាំទ្រថ្មីៗសម្រាប់ការគ្រប់គ្រងយ៉ាងត្រឹមត្រូវនូវសេវាបរិស្ថាននិងសុខភាព
- បង្កើតយន្តការដើម្បីធ្វើឱ្យមន្ត្រីទទួលខុសត្រូវផ្នែកបរិស្ថាននិងសុខភាព អាចអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវវិធីសាស្ត្រសមស្រប និងអាចបញ្ជូនព័ត៌មានស្តីពីលទ្ធផលនិងការបកស្រាយនានាចំពោះភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព
- បង្កើតប្រព័ន្ធការងារសមស្របនិងនីតិវិធីវាយតម្លៃលទ្ធផលការងាររបស់បុគ្គលិករដ្ឋនិងអ្នកវិនិយោគដើម្បីលើកទឹកចិត្តពួកគេឲ្យប្រើពេលវេលានិងកិច្ចខិតខំប្រឹងប្រែងឲ្យបានច្រើន ក្នុងការអភិវឌ្ឍជំនាញដែលចាំបាច់ ក្នុងការអនុវត្តនូវការទទួលខុសត្រូវរបស់ខ្លួន

- បង្កើតយន្តការនិងនីតិវិធីនានា ដើម្បីតាមដានសមិទ្ធកម្មនៃសេវាគាំទ្រចំពោះបរិស្ថាននិងសុខភាព ដើម្បីបំពេញតាមតម្រូវការបច្ចុប្បន្ននិងអនាគត
- រៀបចំនិងអនុវត្តផែនការសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ(ឧបករណ៍ ឯកសារ និងសុហ្វវែរ បរិក្ខារបរិវត្ត មន្ទីរពិសោធន៍។ល។)សម្រាប់រយៈពេលខ្លី មធ្យម និងវែង។

## ៤.៦- ការបណ្តុះបណ្តាលនិងការអប់រំវិជ្ជាជីវៈ

- ដាក់បញ្ចូលវគ្គសិក្សាអំពីបរិស្ថាននិងសុខភាពនៅតាមគ្រឹះស្ថានសិក្សានានា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នផ្សេងៗ ដើម្បីបង្កើនចំណេះដឹងអំពីបរិស្ថាននិងសុខភាពសម្រាប់អ្នកវិជ្ជាជីវៈជំនាន់ក្រោយ
- រៀបចំវគ្គសិក្សាផ្លូវការដែលពាក់ព័ន្ធទៅនឹងបញ្ហាបរិស្ថាននិងសុខភាព
- បង្កើតនិងអនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈបំប៉នបន្ថែម សម្រាប់បុគ្គលមកពីក្រុមភាគីពាក់ព័ន្ធដែលចាំបាច់ត្រូវយល់ដឹងអំពីគោលការណ៍និងការអនុវត្តបរិស្ថាននិងសុខភាព
- បង្កើតនិងអនុវត្តកម្មវិធីនានា ដែលរៀបចំឡើងដើម្បីផ្តល់នូវការបណ្តុះបណ្តាលក្នុងពេលបំពេញការងារ ដល់បុគ្គលដែលមានចំណេះដឹងជំនាញអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬអំពីទិដ្ឋភាពជំនាញនៃការវាយតម្លៃផលប៉ះពាល់សុខភាព។ ត្រូវពិចារណាក្នុងការបណ្តុះបណ្តាលទាំងវគ្គសិក្សាថ្នាក់ឧត្តមសិក្សា វគ្គសិក្សាខ្លីៗ ក្នុងពេលបំពេញការងារ និងកម្មវិធីថ្នាក់ក្រោយឧត្តមសិក្សា
- រៀបចំសិក្ខាសាលានិងកិច្ចពិភាក្សាជាទៀងទាត់សម្រាប់ក្រុមភាគីពាក់ព័ន្ធ ដូចជា អ្នកពិគ្រោះយោបល់ អ្នកវិទ្យាសាស្ត្រ និងក្រុមផ្សេងៗទៀត ដែលមានចំណាប់អារម្មណ៍ពិសេសអំពីបរិស្ថាននិងសុខភាព
- រៀបចំនិងអនុវត្តកម្មវិធី ដើម្បីអភិវឌ្ឍចំណេះដឹងនិងជំនាញរបស់បុគ្គលិកអំពីវិធីសាស្ត្រស្រាវជ្រាវជាពិសេស បុគ្គលិកសុខាភិបាលនិងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រសុខភាព។

## ៤.៧- ការអប់រំនិងការផ្សព្វផ្សាយសាធារណៈ

- ពិនិត្យមើលឡើងវិញទៅលើព័ត៌មានសាធារណៈនិងយុទ្ធសាស្ត្រចូលរួមជាសាធារណៈ ដែលបាន និងកំពុងប្រើនៅក្នុងប្រទេសដទៃមួយចំនួនដើម្បីកំណត់ថា តើដំណើរការណាខ្លះមានភាពសមស្រប សម្រាប់ប្រទេសកម្ពុជា
- បង្កើតកម្មវិធីអប់រំអំពីបរិស្ថាននិងសុខភាពនៅក្នុងគ្រឹះស្ថានសិក្សា
- បង្កើតកម្មវិធីអប់រំនិងផ្សព្វផ្សាយដើម្បីបង្កើនគុណភាពនិងបរិមាណនៃព័ត៌មានដែលអាចរកបាន សម្រាប់ភាគីពាក់ព័ន្ធទាំងអស់
- បង្កើតកម្មវិធីអប់រំនិងផ្សព្វផ្សាយសម្រាប់បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយអំពីបញ្ហាបរិស្ថាននិងសុខភាព ដើម្បីឱ្យពួកគេមានលទ្ធភាពនិងសមត្ថភាពឱ្យកាន់តែប្រសើរ ក្នុងការផ្តល់និងទទួលយោបល់ដែលមានព័ត៌មានគ្រប់គ្រាន់។

## ៤.៨- ការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យា

- លើកទឹកចិត្តឱ្យមានការស្រាវជ្រាវនៅក្នុងវិស័យនានា ដូចជា៖
    + ការវាយតម្លៃប៉ារ៉ាម៉ែត្របរិស្ថាននិងសូចនាករស្ថានភាពសុខភាពនៅថ្នាក់មូលដ្ឋាន
    + ការវាយតម្លៃបទពិសោធអន្តរជាតិដែលបានជោគជ័យ សម្រាប់ការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា

+ ការកំណត់ពីកត្តាហានិភ័យលើបរិស្ថាននិងសុខភាព និងក្រុមជនងាយរងគ្រោះ
+ ការបង្កើតនិងការវាយតម្លៃលើបញ្ជីផ្ទៀងផ្ទាត់និងលើសវនកម្មមុខសញ្ញាគ្រោះថ្នាក់ផ្នែកបរិស្ថាននិងស្ថានភាពសុខភាព សម្រាប់ការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា

- វាយតម្លៃយ៉ាងប្រុងប្រយ័ត្នចំពោះវិធីសាស្ត្រត្រួតពិនិត្យឱ្យមានជោគជ័យ
- ប្រៀបធៀបរាល់ទិន្នន័យអំពីស្ថានភាពបរិស្ថាននិងសុខភាពដែលពាក់ព័ន្ធទាំងអស់ និងពិនិត្យវិធីសាស្ត្រនានាដើម្បីអភិវឌ្ឍបន្ថែមចំពោះមូលដ្ឋានទិន្នន័យនេះ
- កំណត់ប្រសិទ្ធភាពនៃវិធីសាស្ត្រដែលអាចធ្វើការវាយតម្លៃបានរហ័ស សម្រាប់ព្យាករការធ្វើឱ្យកខ្វក់បរិស្ថាន និងហានិភ័យសុខភាព
- ធ្វើការសិក្សាស្រាវជ្រាវដោយប្រើបច្ចេកវិទ្យា ដែលមានអត្ថប្រយោជន៍សម្រាប់វាយតម្លៃការបំពុលបរិស្ថាន
- កែលម្អនិងខិតខំប្រឹងប្រែងស្រាវជ្រាវមុននឹងបង្កើត អនុវត្តកម្មវិធី ឬកិច្ចការអភិវឌ្ឍនានា។

### ៤.៩- កិច្ចសហការអន្តរជាតិ

- បង្កើតបណ្តាញសហការនៅក្នុងវិស័យគន្លឹះអំពីបរិស្ថាននិងសុខភាព តាមរយៈបណ្តាញថ្នាក់តំបន់ដូចជាក្រុមការងារបច្ចេកទេសដែលបង្កើតឡើងនៅក្នុងតំបន់
- រួមចំណែកចំពោះកិច្ចប្រជុំអន្តរជាតិនិងវេទិកាដទៃទៀត ដើម្បីលើកស្ទួយបរិស្ថាននិងសុខភាពនៅក្នុងតំបន់
- សហការជាមួយទីភ្នាក់ងារអន្តរជាតិនានា ដើម្បីលើកកម្ពស់បទដ្ឋានបរិស្ថាននិងសុខភាពសម្រាប់ប្រទេសទាំងអស់នៅក្នុងតំបន់
- ចូលរួមនៅក្នុងកម្មវិធីអន្តរជាតិនានា ដើម្បីបង្កើតបទដ្ឋានអន្តរជាតិសម្រាប់ប៉ារ៉ាម៉ែត្របរិស្ថាន ដែលប៉ះពាល់ដល់សុខភាពមនុស្ស រួមទាំងបញ្ហានានា ដូចជាការប្រែប្រួលអាកាសធាតុ។

### ៤.១០- សុខដុមនីយកម្មវិស័យនានា

គោលនយោបាយនេះ តម្រូវឱ្យមានសុខដុមនីយកម្មលើគោលនយោបាយអភិវឌ្ឍន៍នៃវិស័យនីមួយៗ ដែលពាក់ព័ន្ធផ្នែកសាធារណៈនិងឯកជន ដើម្បីឱ្យមានភាពសមស្របជាមួយការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិស្តីពីបរិស្ថាននិងសុខភាព រួមមាន អភិវឌ្ឍន៍ជនបទ ផែនការ ធនធានទឹក ឧតុនិយម ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម រុក្ខាប្រមាញ់ នេសាទ ព័ត៌មាន អប់រំ វប្បធម៌ សង្គមកិច្ច ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សាធារណការ ដឹកជញ្ជូន ប្រៃសណីយ៍ ទូរគមនាគមន៍ ពាណិជ្ជកម្ម ហិរញ្ញវត្ថុ រៀបចំដែនដី នគរូបនីយកម្ម សំណង់ ទេសចរណ៍ មជ្ឈមណ្ឌលស្រាវជ្រាវ និងវិស័យពាក់ព័ន្ធផ្សេងៗទៀត។

## ៥- ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

### ៥.១- ការបង្កើតយន្តការ

- ត្រូវមានគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ជាយន្តការសម្របសម្រួលថ្នាក់ជាតិនិងពិគ្រោះយោបល់ លើបញ្ហាបរិស្ថានដែលប៉ះពាល់ដល់សុខភាពសាធារណៈ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍន៍ក្នុងការពង្រឹងកិច្ចសហការរវាងក្រសួងនិងទីភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការប្រកាសឱ្យប្រើគោលនយោបាយនេះ ដើម្បីធានាថារាល់វិស័យទាំងអស់មានការយល់ដឹងដូចគ្នា ហើយគោលនយោបាយជាតិបរិស្ថាននិងសុខភាពធ្វើសុខដុមនីយកម្មជាមួយគោលនយោបាយបរិស្ថាន

- ត្រូវមានភ្នាក់ងារត្រួតពិនិត្យបរិស្ថាននិងសុខភាពនៅគ្រប់លំដាប់ថ្នាក់ (ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) ដែលទទួលខុសត្រូវ ចំពោះការប៉ាន់ប្រមាណនិងការវាយតម្លៃផលប៉ះពាល់សុខភាព បន្ថែមពីលើភ្នាក់ងារនានាដែលទទួលខុសត្រូវចំពោះហេតុប៉ះពាល់បរិស្ថាន ហើយភ្នាក់ងារដទៃទៀត ចាំបាច់ត្រូវតែចូលរួមសហប្រតិបត្តិការ
- ត្រូវមានក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដែលមានតួនាទី ភារកិច្ចផ្តួចផ្តើមរៀបចំគោលនយោបាយ ផែនការសកម្មភាព និងអនុវត្តគម្រោង ស្របតាមជំនាញបច្ចេកទេសដោយឡែកពីគ្នា
- អាចបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងសភាពាណិជ្ជកម្ម អង្គភាពវិជ្ជាជីវៈនិងបច្ចេកទេស សាធារណជន និងអ្នកពិគ្រោះយោបល់អាជីវកម្មវិស័យសាធារណៈ និងឯកជន(ខ្នាតធំ មធ្យម និងតូច) ដែលមានសក្តានុពលក្នុងការចូលរួមនៅក្នុងប្រតិបត្តិការនានា ដែលអាចជះឥទ្ធិពលលើបរិស្ថាននិងសុខភាព ប្រព័ន្ធផ្សព្វផ្សាយ ទំនាក់ទំនងសាធារណៈ សេវាព័ត៌មាន សាកលវិទ្យាល័យ មជ្ឈមណ្ឌលស្រាវជ្រាវ សមាគមអ្នកវិទ្យាសាស្ត្រ និងអង្គការអន្តរជាតិ
- បង្កើតយន្តការផ្សេងទៀតដែលចាំបាច់។

### ៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

- ត្រូវមានគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាពដែលត្រូវកំណត់ដោយអនុក្រឹត្យ។ គណៈកម្មាធិការជាតិបរិស្ថាននិងសុខភាពនេះ ស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ សមាសភាពរបស់គណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល
- ត្រូវមានក្រុមការងារបច្ចេកទេស ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព
- រៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពារបរិស្ថាននិងសុខភាព និងផែនការសកម្មភាពជាតិបរិស្ថាននិងសុខភាព ដែលត្រូវសម្រេចដោយគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព
- រៀបចំបទប្បញ្ញត្តិស្តីពីការវាយតម្លៃផលប៉ះពាល់សុខភាព
- រៀបចំច្បាប់ស្តីពីការការពារបរិស្ថាននិងសុខភាព
- រៀបចំគោលនយោបាយ ផែនការសកម្មភាពសមស្របតាមវិស័យពាក់ព័ន្ធនានា ដែលកំណត់នូវសកម្មភាពជាក់លាក់ ត្រូវកំណត់ការទទួលខុសត្រូវដល់ក្រសួងស្ថាប័នពាក់ព័ន្ធ
- រៀបចំភ្នាក់ងារត្រួតពិនិត្យបរិស្ថាននិងសុខភាព ដែលត្រូវសម្រេចដោយស្ថាប័នទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់
- ពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា។

### ៥.៣- ការគាំទ្រហិរញ្ញវត្ថុ

គណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព គឺជាយន្តការសម្របសម្រួលថ្នាក់ជាតិទទួលបន្ទុក និងតាមដានការអនុវត្តគោលនយោបាយជាតិ ហើយរាល់ការចំណាយសម្រាប់កិច្ចការនានា គឺមានប្រភពផ្គត់ផ្គង់ដោយថវិកាជាតិ ជាកម្មវិធីនៅក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល។

រាល់ការអនុវត្តផែនការសកម្មភាព មានប្រភពផ្គត់ផ្គង់ដោយថវិកាជាតិជាកម្មវិធីនៅក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ និងពីប្រភពផ្សេងទៀតរបស់ដៃគូអភិវឌ្ឍនានា និងអង្គការមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធក្នុងវិស័យទាំងនេះ។

៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីបរិស្ថាននិងសុខភាព ត្រូវយកចិត្តទុកដាក់រៀបចំនិងអនុវត្តគម្រោងកម្មវិធីសិក្សារយៈពេលយូរ និងរយៈពេលខ្លី ដើម្បីបង្កើនចំណេះដឹងអំពីបរិស្ថាននិងសុខភាពសម្រាប់អ្នកវិជ្ជាជីវៈជំនាន់ក្រោយ និងដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញ ដល់មន្ត្រីទទួលខុសត្រូវអំពីវិធីសាស្ត្រស្រាវជ្រាវ ត្រួតពិនិត្យ តាមដានវាយតម្លៃផលប៉ះពាល់សុខភាព។

៥.៥- ដំណើរការអនុវត្តគម្រោង

តាមរយៈយុទ្ធសាស្ត្រនៃគោលនយោបាយជាតិស្តីពីបរិស្ថាននិងសុខភាព សំណុំគោលដៅរយៈពេលខ្លី មធ្យម និងរយៈពេលវែង ត្រូវបានយកមកអនុវត្តដោយមានការពិគ្រោះយោបល់ពីគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ដែលស្របទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជានិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

## ៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីធានាឱ្យគោលនយោបាយនេះអនុវត្តបានជោគជ័យ អាចសម្រេចបានលទ្ធផលដូចបានរំពឹងទុកប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព ចាំបាច់ត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ ការពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្ត ដោយផ្តោតលើសូចនាករដូចខាងក្រោម៖

- ក្របខ័ណ្ឌច្បាប់និងស្ថាប័នសម្រាប់បរិស្ថាននិងសុខភាព ត្រូវបានកែសម្រួលនិងបង្កើតឡើង ហើយប្រព័ន្ធនៃការកំណត់ការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃ ត្រូវបានកែលម្អ
- ប្រភពនិងមូលហេតុធ្វើឱ្យកខ្វក់ផ្នែកបរិស្ថាននិងកត្តាហានិភ័យផ្នែកបរិស្ថាន និងសុខភាពនានាត្រូវបានកំណត់ និងមានការកំណត់ពីទំនាក់ទំនងរវាងកត្តាបរិស្ថាននិងស្ថានភាពសុខភាព
- ការកសាងសមត្ថភាពមនុស្សលើវិស័យបរិស្ថាននិងសុខភាព និងសមត្ថភាពមន្ទីរពិសោធន៍ ត្រូវបានកែលម្អនិងពង្រឹងបន្ថែម
- កម្រិតនៃការអប់រំរបស់ប្រជាជនអំពីបរិស្ថាននិងសុខភាពត្រូវបានបង្កើន ហើយការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាព និងកម្មវិធីផ្សព្វផ្សាយអំពីបរិស្ថាន និងសុខភាព ក៏ត្រូវបានបង្កើនផងដែរ
- សូចនាករបរិស្ថាននិងសុខភាពជាមូលដ្ឋាននៅទីក្រុងត្រូវបានកែលម្អ
- ជំងឺនិងមរណភាពដែលបណ្តាលដោយផ្ទាល់មកពីកត្តាហានិភ័យផ្នែកបរិស្ថាន ដែលមានលក្ខណៈផ្នែករូបសាស្ត្រ គីមីសាស្ត្រ ឬជីវសាស្ត្រ ត្រូវបានកាត់បន្ថយ ដូចមាននៅក្នុងគោលដៅសុខភាព ដែលកំណត់ដោយក្រសួងសុខាភិបាល សម្រាប់ឆ្នាំ២០០៨-២០១៥ (ផែនការយុទ្ធសាស្ត្រសុខាភិបាល ជំហានទីពីរ)។

## ៧- សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានឱ្យតម្លៃខ្ពស់ទៅលើការផ្តល់ស្តង់ដាសុខភាពប្រសើរបំផុត សម្រាប់ប្រជាជនទាំងអស់ ជាពិសេស ការយកចិត្តទុកដាក់ចំពោះប្រជាជនក្រីក្រនិងជនងាយរងគ្រោះ។ ការអនុវត្តគោលនយោបាយជាតិស្តីពីបរិស្ថាននិងសុខភាព ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចំពោះបរិស្ថាននិងសុខភាព ដែលបណ្តាលឱ្យស្លាប់ មានជំងឺ បង្កបង្ហូសនៅក្នុងចំណោមប្រជាជនកម្ពុជា ធានាថា ផលប៉ះពាល់វិជ្ជមានត្រូវបានបង្កើនជាអតិបរមា ហើយផលប៉ះពាល់អវិជ្ជមានត្រូវបានកាត់បន្ថយឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមាតាមដែលអាចធ្វើទៅបាន។

រាជរដ្ឋាភិបាលមានការជឿជាក់ចំពោះការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រឹងកិច្ចសហការនិងកិច្ចសហប្រតិបត្តិការជាមួយវិស័យផ្សេងៗទៀត ទាំងផ្នែកសាធារណៈ ទាំងផ្នែកឯកជន និងសហគមន៍ ដើម្បីកាត់បន្ថយរាល់កត្តាហានិភ័យផ្នែករូបសាស្ត្រ គីមី និងជីវសាស្ត្រទាំងអស់ នៅក្នុងបរិស្ថាន និងការលើកកម្ពស់សុខភាព ដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

## ៨- សន្ទានុក្រម

**សុខភាព (Health)**

ភាពសុខដុមរមនានៃផ្លូវកាយនិងផ្លូវចិត្តរបស់មនុស្ស រស់នៅប្រកបដោយសុខុមាលភាព ពុំមានការឈឺថ្កាត់ និងពិការភាពអ្វីមកបៀតបៀន។

**បរិស្ថាន (Environment)**

លក្ខណៈសរីរាង្គឬអសរីរាង្គដែលកើតមកពីធម្មជាតិឬមនុស្សជាអ្នកបង្កើត និងជាមជ្ឈដ្ឋានដែលរស់នៅជុំវិញដូចជា មនុស្ស សត្វ រុក្ខជាតិ និងអ្វីៗផ្សេងទៀត ដែលមានអន្តរកម្មវិជ្ជមាននិងអវិជ្ជមាន និងទទួលនូវផលប៉ះពាល់លើគ្នាទៅវិញទៅមក ទោះបីជាមានលក្ខណៈគ្រោះថ្នាក់ឬអនុគ្រោះចំពោះនិរន្តរភាពនៃជីវិតនិងការអភិវឌ្ឍរបស់មនុស្ស។

**បរិស្ថាននិងសុខភាព( Environmental Health)**

ទិដ្ឋភាពទាំងឡាយនៃសុខភាពមនុស្ស រួមទាំងគុណភាពជីវិត ដែលត្រូវបានកំណត់ដោយកត្តារូបសាស្ត្រ គីមី ជីវសាស្ត្រ សង្គម និងចិត្តសាស្ត្រនៅក្នុងបរិស្ថាន។ បរិស្ថាននិងសុខភាព ក៏សំដៅផងដែរដល់ទ្រឹស្តីនិងការអនុវត្ត ការវាយតម្លៃ ការកែតម្រូវ ការត្រួតពិនិត្យ និងការទប់ស្កាត់កត្តាទាំងអស់នៅក្នុងបរិស្ថាន ដែលអាចប៉ះពាល់ជាអវិជ្ជមានចំពោះសុខភាពរបស់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត(អង្គការសុខភាពពិភពលោក)។ បរិស្ថាននិងសុខភាព គឺជាមូលដ្ឋានគ្រឹះនៃសុខភាពសាធារណៈ និងផ្តល់នូវមូលដ្ឋានសម្រាប់សង្គមទំនើប។

**ការវាយតម្លៃផលប៉ះពាល់សុខភាព (Health Impact Assessment . HIA)**

ការរួមបញ្ចូលគ្នានូវនីតិវិធី វិធីសាស្ត្រ និងឧបករណ៍ បង្ហាញពីផលប៉ះពាល់ដែលអាចនឹងកើតមានឡើងឬជូនកាល ផលប៉ះពាល់ដែលមិនបានគ្រោងទុករបស់គោលនយោបាយ ផែនការ កម្មវិធី ឬគម្រោងកម្មវិធីស្តីពីសុខភាពរបស់ប្រជាពលរដ្ឋ និងរបាយនៃផលប៉ះពាល់ទាំងនោះនៅក្នុងចំណោមប្រជាពលរដ្ឋ។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (Environment Impact Assessment . EIA)**

នីតិវិធីវាយតម្លៃហានិភ័យតាមបែបគុណភាពនិងបរិមាណនៃហេតុប៉ះពាល់ ជាសក្តានុពលវិជ្ជមានឬអវិជ្ជមានលើបរិស្ថាន នូវរាល់គោលនយោបាយ គម្រោង និងកម្មវិធីថ្មីៗទាំងអស់ ដោយផ្តោតទៅលើទិដ្ឋភាពបរិស្ថាន សង្គម និងសេដ្ឋកិច្ច។